EPA VICTORIA



# ដែលអាចអនុវត្តបានដោយសមហេតុផល

ការបោះពុម្ពផ្សាយលេខ1856 ខែកញ្ញា ឆ្នាំ 2020

VICTORIA State Government

ការបោះពុម្ពផ្សាយលេខ 1856 ខែកញ្ញា ឆ្នាំ 2020

**ការបដិសេធទទួលខុសត្រូវ**

ព័ត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសម្រាប់តែការណែនាំទូទៅប៉ុណ្ណោះ។ វាមិនបង្កើតដំបូន្មានផ្នែកច្បាប់ ឬវិជ្ជាជីវៈផ្សេងទៀតទេ ហើយមិនគួរពឹងផ្អែកជាសេចក្តីថ្លែងការណ៍នៃច្បាប់ឡើយ។ ដោយសារវាមានគោលបំណងសម្រាប់តែការណែនាំទូទៅប៉ុណ្ណោះ ដូច្នេះ វាអាចផ្ទុកព័ត៌មានដែលមានលក្ខណៈទូទៅ។

អ្នកគួរតែទទួលយកដំបូន្មានពីអ្នកមានវិជ្ជាជីវៈ ប្រសិនបើអ្នកមានការព្រួយបារម្ភជាក់លាក់ណាមួយ។ EPA បានខិតខំប្រឹងប្រែងដោយសមរម្យ ដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្ន និងត្រឹមត្រូវ ប៉ុន្តែមិនធ្វើការធានាណាមួយទាក់ទងនឹងភាពត្រឹមត្រូវ បច្ចុប្បន្នភាព ឬភាពពេញលេញនៃព័ត៌មានឡើយ។

© រដ្ឋវិចថូរៀ (អាជ្ញាធរការពារបរិស្ថាន វិចថូរៀ) ឆ្នាំ 2020។

ព័ត៌មាននេះ *ដែលអាចអនុវត្តបានដោយសមហេតុផល* ត្រូវបានផ្តល់អាជ្ញាប័ណ្ណក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution 4.0 ។ អ្នកមានសេរីភាពក្នុងការប្រើប្រាស់ព័ត៌មាននេះឡើងវិញក្រោមអាជ្ញាប័ណ្ណនេះ ក្រោមលក្ខខណ្ឌថា អ្នកត្រូវផ្តល់ការទទួលស្គាល់អាជ្ញាធរការពារបរិស្ថាន វិចថូរៀ (EPA វិចថូរៀ) ថាជាអ្នកនិពន្ធ ហើយត្រូវចង្អុលបង្ហាញ ប្រសិនបើមានការផ្លាស់ប្តូរត្រូវបានធ្វើឡើង និងត្រូវគោរពតាមលក្ខខណ្ឌដទៃទៀតរបស់អាជ្ញាប័ណ្ណ។ អាជ្ញាប័ណ្ណមិនអនុវត្តចំពោះ៖ រូបថត និងរូបភាពណាមួយ ស្លាកយីហោណាមួយ រួមទាំងនិមិត្តសញ្ញារបស់ EPA និងនិមិត្តសញ្ញារបស់រដ្ឋាភិបាលរដ្ឋវិចថូរៀ ហើយនិងមាតិកាដែលផ្តល់ដោយភាគីទីបីឡើយ។

អនុញ្ញាត និងបោះពុម្ពផ្សាយដោយ
អាជ្ញាធរការពារបរិស្ថាន វិចថូរៀ
200 Victoria Street, Carlton VIC 3053
**វិបសៃថ៍** epa.vic.gov.au | **ទូរសព្ទ** 1300 372 842 (1300 EPA VIC)

Interpreter

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ ឬចង់ឱ្យគេបកប្រែឯកសារនេះជូនអ្នក សូមទូរសព្ទទៅលេខ **131 450** ហើយប្រាប់អំពីភាសាដែលអ្នកចង់បាន។

ប្រសិនបើអ្នកថ្លង់ ឬមានបញ្ហាខ្សោយក្នុងការស្តាប់ ឬនិយាយ សូមទាក់ទងមកយើងតាមរយៈ: សេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល **www.relayservice.gov.au**

## មាតិកា


ទិដ្ឋភាពទូទៅ ........ 3

វិធីកំណត់ថាអ្វីដែលអាចអនុវត្តបានដោយសមហេតុផល ........ 4

1. លុបបំបាត់ជាមុន ........ 7
   ចុះប្រសិនបើខ្ញុំមិនអាចលុបបំបាត់ហានិភ័យរបស់ខ្ញុំ? ........ 8
2. ភាពនឹងអាចកើតមាន ........ 8
3. កម្រិត (ឬផលវិបាក) ........ 9
4. ចំណេះដឹងអំពីហានិភ័យ ........ 10
5. ភាពអាចរកបាន និងភាពសមស្រប ........ 11
6. ថ្លៃចំណាយ ........ 13

ដែលអាចអនុវត្តបានដោយសមហេតុផល អាចវិវត្តទៅតាមពេលវេលា ........ 15

ធនធានដែលមាន ........ 16


## ទិដ្ឋភាពទូទៅ

នៅរដ្ឋវិចថូរៀ ច្បាប់ថ្មីនឹងចូលជាធរមាន គឺជាច្បាប់ដែលបានបង្កើតឡើងដើម្បីទប់ស្កាត់គ្រោះថ្នាក់ដល់សុខភាពមនុស្ស និងបរិស្ថានពីការបំពុល និងកាកសំណល់។

ផ្នែកសំខាន់បំផុតនៃ *ច្បាប់ការពារបរិស្ថាន ឆ្នាំ 2017* (ច្បាប់)[1] គឺជា **កាតព្វកិច្ចបរិស្ថានទូទៅ**(GED)។

GED គឺជាវិធីសាស្ត្រថ្មីមួយ ដែលផ្តោតលើការទប់ស្កាត់គ្រោះថ្នាក់ពីកាកសំណល់ និងការបំពុល ជាជាងការគ្រប់គ្រងផលប៉ះពាល់ បន្ទាប់ពីគ្រោះថ្នាក់បានកើតឡើងរួចហើយ។

ក្រោមច្បាប់នេះ មានកាតព្វកិច្ចបីតម្រូវឱ្យអ្នកកាត់បន្ថយ ឬឆ្លើយតបនឹងហានិភ័យ ឱ្យដល់កម្រិតដែលអាចអនុវត្តបានដោយសមហេតុផល។

ការណែនាំនេះនឹងផ្តោតលើកាតព្វកិច្ចពីរ គឺ៖

### កាតព្វកិច្ចបរិស្ថានទូទៅ[2]

GED តម្រូវថា
*'ជនណាមួយដែលកំពុងចូលរួមក្នុងសកម្មភាពដែលអាចបង្កើនហានិភ័យនៃគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬបរិស្ថាន ពីការបំពុល ឬកាកសំណល់ ត្រូវតែកាត់បន្ថយហានិភ័យទាំងនោះ ឱ្យដល់កម្រិតដែលអាចអនុវត្តបានដោយសមហេតុផល*។

### កាតព្វកិច្ចដើម្បីគ្រប់គ្រងដីដែលបានធ្វើឱ្យកខ្វក់[3]

ប្រសិនបើអ្នកនៅក្នុងការគ្រប់គ្រងនៃដីដែលបានធ្វើឱ្យកខ្វក់
*'អ្នកត្រូវតែកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងបរិស្ថាន ពីដីដែលបានធ្វើឱ្យកខ្វក់នោះ ឱ្យដល់កម្រិត ដែលអាចអនុវត្តបានដោយសមហេតុផល*។

កាតព្វកិច្ចដើម្បីធ្វើសកម្មភាពឆ្លើយតបនឹងគ្រោះថ្នាក់ ដែលបណ្តាលមកពីឧប្បត្តិហេតុនៃការបំពុល[4] ក៏តម្រូវឱ្យអ្នកឆ្លើយតបឱ្យដល់កម្រិតដែលអាចអនុវត្តបានដោយសមហេតុផលផងដែរ ។ នេះនឹងក្លាយជាប្រធានបទនៃការណែនាំដាច់ដោយឡែក។

[1] ដូចដែលបានធ្វើវិសោធនកម្មដោយ *ច្បាប់វិសោធនកម្មការពារបរិស្ថាន ឆ្នាំ 2018*។
[2] ផ្នែក25 នៃ *ច្បាប់ការពារបរិស្ថាន ឆ្នាំ 2017* (ដូចដែលបានធ្វើវិសោធនកម្មដោយ *ច្បាប់វិសោធនកម្មការពារបរិស្ថាន ឆ្នាំ 2018*)។ [3] ផ្នែក 39 នៃ *ច្បាប់ការពារបរិស្ថាន ឆ្នាំ 2017* (ដូចដែលបានធ្វើវិសោធនកម្មដោយ *ច្បាប់វិសោធនកម្មការពារបរិស្ថាន ឆ្នាំ 2018*)។ [4] ផ្នែក 31 នៃ *ច្បាប់ការពារបរិស្ថានឆ្នាំ 2017* (ដូចដែលបានធ្វើវិសោធនកម្មដោយ *ច្បាប់វិសោធនកម្មការពារបរិស្ថាន ឆ្នាំ 2018*)។

## វិធីកំណត់អ្វីដែលអាចអនុវត្តបានដោយសមហេតុផល

ការធ្វើអ្វី**ដែលអាចអនុវត្តបានដោយសមហេតុផល** មានន័យថា *អ្នកត្រូវតែ ដាក់ការគ្រប់គ្រងតាមសមាមាត្រដើម្បីធ្វើឱ្យធូរស្រាល ឬកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់។*




**ការគ្រប់គ្រង** ដែលលុបបំបាត់ ឬដាក់ជំនួសប្រភពនៃហានិភ័យ គឺមានប្រសិទ្ធភាពបំផុត បន្ទាប់មកគឺការគ្រប់គ្រងបែបវិស្វកម្ម ឬការគ្រប់គ្រងអគារ ហើយទីបំផុតការបណ្តុះបណ្តាល និងការអនុវត្តនៅតាមទីតាំង។ ជាញឹកញាប់ ការរួមបញ្ចូលគ្នានៃការគ្រប់គ្រងទាំងអស់នេះគឺជាការចាំបាច់។




ស្របតាម**សមាមាត្រ** មានន័យថាហានិភ័យនៃគ្រោះថ្នាក់កាន់តែច្រើន ការរំពឹងទុកសម្រាប់អ្នកដើម្បីគ្រប់គ្រងវាក៏កាន់តែច្រើនដែរ។ អ្នកធ្វើដូច្នេះតាមរយៈការបង្ហាញថាអ្នកបានពិចារណា និងអនុវត្តការត្រួតពិនិត្យដែលសមស្របបំផុតដែលមាន ដើម្បីលុបបំបាត់ ឬកាត់បន្ថយគ្រោះថ្នាក់។

# ដែលអាចអនុវត្តបានដោយសមហេតុផល

នៅពេលអ្នកដោះស្រាយហានិភ័យទូទៅ ឬគ្រោះថ្នាក់ទូទៅ ជាញឹកញាប់អ្នកអាចបង្ហាញថា អ្នកបានធ្វើអ្វីដែលអាចអនុវត្តបានដោយសមហេតុផល ប្រសិនបើ៖

- អ្នកបានទទួលយកប្រើនូវការអនុវត្ត ឬការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដែលបានបង្កើតឡើងយ៉ាងល្អដើម្បីលុបបំបាត់ ឬគ្រប់គ្រងហានិភ័យ និង/ឬ
- កន្លែងណាដែលមិនមានការអនុវត្ត ឬការគ្រប់គ្រងដែលបានបង្កើតឡើងយ៉ាងល្អ អ្នកបង្ហាញថាអ្នកបានវាយតម្លៃ និងទទួលយកប្រើនូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

ឧទាហរណ៍ ហានិភ័យទូទៅចំពោះបរិស្ថានគឺការកំពប់ប្រេងពីធុងប្រេង។ ការពិចារណាលើហានិភ័យ និងការគ្រប់គ្រងសមស្របដែលអាចមានដើម្បីលុបបំបាត់ ឬកាត់បន្ថយគ្រោះថ្នាក់ មានន័យថាអ្នកអាចពិចារណាបញ្ហានានាដូចជា៖




ការណែនាំពី EPA និងពីឧស្សាហកម្ម អាចជួយអ្នកក្នុងការស្វែងរក៖

- ការអនុវត្តទូទៅ និងមានប្រសិទ្ធភាព
- ជំហាននានាដែលត្រូវអនុវត្តតាមដើម្បីវាយតម្លៃហានិភ័យ
- ការត្រួតពិនិត្យដើម្បីលុបបំបាត់ ឬគ្រប់គ្រងហានិភ័យ។

ក្នុងករណីខ្លះ អ្នកប្រហែលជាចាំបាច់ត្រូវស្វែងរកជម្រើសបន្ថែមទៀត ដើម្បីគ្រប់គ្រងហានិភ័យរបស់អ្នក។ កន្លែងណាដែលមិនមានការណែនាំពី EPA ឬពីឧស្សាហកម្ម ឬកន្លែងណាដែលវិធីសាស្ត្រមួយចំនួនអាចមានប្រសិទ្ធភាព សូមស្វែងរកដំបូន្មានបន្ថែម។

វាជាកាតព្វកិច្ចរបស់អ្នកក្នុងការស្វែងយល់ពីហានិភ័យរបស់អ្នក និងវិធីសាស្ត្រត្រឹមត្រូវក្នុងការគ្រប់គ្រងវា។

# ដែលអាចអនុវត្តបានដោយសមហេតុផល

ដើម្បីកំណត់ថាអ្វីដែលអាចអនុវត្តបានដោយសមហេតុផល វាសំខាន់ក្នុងការពិចារណាពីកម្រិត ឬទំហំនៃហានិភ័យ ឬគ្រោះថ្នាក់ពីសកម្មភាពរបស់អ្នក ឧប្បត្តិហេតុនៃការបំពុល ឬដីដែលបានធ្វើឱ្យកខ្វក់។

ដើម្បីបង្ហាញថា អ្នកបានគិតអំពីអ្វីដែលអាចអនុវត្តបានដោយសមហេតុផល សូមពិចារណាពី**កត្តាទាំងប្រាំមួយនេះ៖**

1. **លុបបំបាត់ជាមុន៖**តើអ្នកអាចលុបបំបាត់ហានិភ័យបានឬទេ?
2. **ភាពនឹងអាចកើតមាន៖** តើមានឱកាសដែលគ្រោះថ្នាក់នឹងកើតមានឬទេ?
3. **កម្រិត (ផលវិបាក)៖** តើគ្រោះថ្នាក់អាចប៉ះពាល់ដល់សុខភាពមនុស្ស ឬបរិស្ថានធ្ងន់ធ្ងរយ៉ាងណាដែរ?
4. **ចំណេះដឹងរបស់អ្នកអំពីហានិភ័យ៖** តើអ្នកដឹងពីអ្វីខ្លះ ឬតើអ្នកអាចរកឃើញអ្វីខ្លះ អំពីហានិភ័យដែលសកម្មភាពរបស់អ្នកបង្កឡើង?
5. **ភាពអាចរកបាន និងភាពសមស្រប៖**តើបច្ចេកវិទ្យា ដំណើរការ ឬឧបករណ៍អ្វីខ្លះដែលអាចមានដើម្បីគ្រប់គ្រងហានិភ័យបាន? តើមានការគ្រប់គ្រងអ្វីខ្លះដែលសមស្រប សម្រាប់ការប្រើប្រាស់ក្នុងកាលៈទេសៈរបស់អ្នក?
6. **ថ្លៃចំណាយ៖** តើការគ្រប់គ្រងត្រូវចំណាយអស់ប៉ុន្មានដើម្បីបង្កើតឡើងសម្រាប់ប្រើប្រាស់ បើប្រៀបធៀបទៅនឹងប្រសិទ្ធភាពរបស់វាក្នុងការកាត់បន្ថយហានិភ័យ?

អ្នកចាំបាច់ត្រូវពិចារណាកត្តាទាំងនេះជាមួយគ្នា ពីព្រោះវានឹងជួយអ្នកក្នុងការកំណត់ពីអ្វីដែលអាចអនុវត្តបានដោយសមហេតុផល ដើម្បីគ្រប់គ្រងហានិភ័យរបស់អ្នក។

## 1. លុបបំបាត់ជាមុន




**លំដាប់នៃការគ្រប់គ្រង**

វិធានការដែលកាត់បន្ថយហានិភ័យបានច្រើន ត្រូវបាននិយមពេញចិត្តជាងវិធានការដែលមិនសូវមានប្រសិទ្ធភាព ក្នុងការកាត់បន្ថយហានិភ័យ។

1. លុបបំបាត់ភាពបង្គ្រោះថ្នាក់ដើម្បីលុបបំបាត់ហានិភ័យ - នេះគឺជាការគ្រប់គ្រងដែលមានប្រសិទ្ធភាពបំផុត។
2. កាត់បន្ថយហានិភ័យតាមរយៈការដាក់ជំនួស ឬការគ្រប់គ្រងបែបវិស្វកម្មជាក់ស្តែងសម្រាប់ភាពបង្គ្រោះថ្នាក់។
3. ជាចុងក្រោយ ផ្លាស់ប្តូរអាកប្បកិរិយារបស់មនុស្ស តាមរយៈការគ្រប់គ្រងផ្នែករដ្ឋបាល ដូចជានីតិវិធី និងការបណ្តុះបណ្តាល ហើយនិងការប្រើប្រាស់ឧបករណ៍ការពារផ្ទាល់ខ្លួន (PPE)។

ចាប់ផ្តើមដោយពិចារណាពីវិធីដែលអ្នកអាចលុបបំបាត់ហានិភ័យ។ នេះអាចសម្រេចបានតាមរយៈការរៀបចំសកម្មភាពរបស់អ្នកឡើងវិញ ដើម្បីដកចេញប្រភពហានិភ័យដំបូងបំផុត។

*ឧទាហរណ៍៖ Ahmed គ្រប់គ្រងយានដ្ឋានជួសជុលរថយន្តមួយ។ សកម្មភាពរបស់ Ahmed រួមមានការប្តូរប្រេងម៉ាស៊ីនក្នុងរថយន្តនានា ដែលគាត់ធែកពិនិត្យជារៀងរាល់ថ្ងៃ។ ដើម្បីធ្វើសកម្មភាពនេះ យានដ្ឋានជួសជុលមានស្តុកទុកទាំងប្រេងម៉ាស៊ីនថ្មី (មិនទាន់ប្រើ) និងប្រេងម៉ាស៊ីនចាស់ (ប្រើរួចហើយ) នៅនឹងកន្លែង។ ចំនួនប្រេងម៉ាស៊ីនដែលស្តុកទុក អាចបម្រើអតិថិជនជម្មតាដែលគាត់ទទួលយក។*

*Ahmed និងបុគ្គលិករបស់គាត់តែងប្រើប្រេងថ្មីពេញមួយថ្ងៃ។ គាត់មិនមានអារម្មណ៍ថា វាអាចអនុវត្តបានដោយសមហេតុផល ដើម្បី **លុបបំបាត់**ការស្តុកទុកប្រេង ឬកាត់បន្ថយបរិមាណដែលត្រូវស្តុកទុកនៅទីតាំងបានទេ។ Ahmed ស្តុកទុកតែប្រេងម៉ាស៊ីនចាស់នៅនឹងកន្លែងជាបណ្តោះអាសន្នប៉ុណ្ណោះ។ គាត់បានធ្វើការជាមួយក្រុមហ៊ុនដឹកជញ្ជូនកាកសំណល់សមស្របមួយ ដើម្បីផ្ទេរប្រេងម៉ាស៊ីនចាស់ ទៅកន្លែងដែលអាចផ្តុកបានដោយស្របច្បាប់។*

ការកំណត់វិធីដើម្បីលុបបំបាត់ហានិភ័យ គឺធ្វើបានល្អបំផុត *នៅមុនពេលចាប់ផ្តើមសកម្មភាព* ហើយការប្រើឱកាសនានាដែលអ្នកមាន ដើម្បីធ្វើការកំចាត់ហានិភ័យគឺជាគោលដៅមួយ ក្នុងចំណោមគោលដៅនានាក្នុងពេលបង្កើតគម្រោង។

# ដែលអាចអនុវត្តបានដោយសមហេតុផល

## ចុះប្រសិនបើខ្ញុំមិនអាចលុបបំបាត់ហានិភ័យរបស់ខ្ញុំ?

ប្រសិនបើមិនអាចអនុវត្តបានដោយសមហេតុផល ដើម្បីលុបបំបាត់ហានិភ័យបានទេ អ្នកត្រូវពិចារណាពីវិធីដែលអ្នកអាចកាត់បន្ថយហានិភ័យ។

ក្នុងសេណារីយ៉ូនៅទំព័រទី 7 Ahmed អាចកាត់បន្ថយហានិភ័យរបស់គាត់ ដោយពិចារណាពីទីកន្លែង និងវិធីដែលប្រេងនៅក្នុងយានដ្ឋានជួសជុលរបស់គាត់ត្រូវបានប្រើប្រាស់ និងស្តុកទុក។

សូមយោងទៅតាមលំដាប់នៃការគ្រប់គ្រង ហើយសូមអនុវត្តវានៅលើទីតាំងរបស់អ្នក។ ដើម្បីអនុវត្តលំដាប់នៃការគ្រប់គ្រង សូមពិចារណាអំពីកត្តាទាំងនេះ៖

### 2. ភាពនឹងអាចកើតមាន




ពិចារណាអំពី **|ភាពនឹងអាចកើតមាន**ឱកាសនៃគ្រោះថ្នាក់ដែលកើតឡើង។ ភាពនឹងអាចកើតមានកាន់តែច្រើន សារៈសំខាន់របស់វាក៏កាន់តែខ្លាំងដែរ នៅពេលពិចារណាអំពីអ្វីដែលអាចអនុវត្តបានដោយសមហេតុផល។ អ្នកអាចយល់ដឹងពីភាពនឹងអាចកើតមាន ឬលទ្ធភាពនឹងអាចកើតមានដោយពិចារណា៖

- តើសកម្មភាពដែលបង្កើតភាពបង្កគ្រោះថ្នាក់កើតឡើងញឹកញាប់ប៉ុណ្ណា
- តើព្រឹត្តិការណ៍មួយបានកើតឡើងពីមុននៅលើទីតាំរបស់អ្នកឬទេ
- តើគ្រោះថ្នាក់បានកើតឡើងជាទូទៅនៅលើទីតាំងផ្សេងទៀតឬទេ
- ព័ត៌មានពីអ្នកផ្គត់ផ្គង់ ឬអ្នកផលិត។

ប្រសិនបើគ្រោះថ្នាក់ទំនងជាកើតមាន អ្នកនឹងចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការលុបបំបាត់ ឬកាត់បន្ថយហានិភ័យ។

*ឧទាហរណ៍៖ នៅកន្លែងធ្វើការរបស់ Ahmed ប្រេងម៉ាស៊ីនថ្មី និងប្រេងម៉ាស៊ីនចាស់ បច្ចុប្បន្នត្រូវបានស្តុកទុកនៅក្បែរលូបង្ហូរទឹកភ្លៀង។ ប្រេងទាំងនេះក៏នៅក្បែរតំបន់ដែលមានចរាចរណ៍ចេញចូលច្រើនផងដែរ ដែលរថយន្តរង់ចាំសេវាកម្មបានចត។ ជាញឹកញាប់ បុគ្គលិកផ្លាស់ទីយានយន្តនៅតំបន់នេះ។ ព្រមទាំងមានបុគ្គលិកម្នាក់យកប្រេងម៉ាស៊ីនចាស់ ទៅកាន់ធុងដាក់ប្រេងម៉ាស៊ីនចាស់ដោយដើរឆ្លងកាត់ច្រកលូបង្ហូរទឹកភ្លៀង ជាច្រើនដងក្នុងមួយថ្ងៃ។*

*Ahmed ដឹងថា ដោយសារតែប្រេងម៉ាស៊ីនម៉ាស៊ីនត្រូវបានស្តុកទុកនៅក្បែរតំបន់ចរាចរណ៍ចេញចូលច្រើន ដូច្នេះ **ភាពនឹងអាចកើតមានខ្ពស់**នៃការកំពប់ដោយសារតែហានិភ័យជាក់ស្តែងនៃការប៉ះពាល់បង្កដោយយានយន្តបណ្តាលឱ្យកំពប់ ឬលេចធ្លាយប្រេង។ គាត់ក៏ដឹងដែរថាមានហានិភ័យដែលប្រេងម៉ាស៊ីនចាស់ អាចកំពប់ដោយសារប្រេងម៉ាស៊ីនចាស់ ត្រូវបានលើកចុះឡើងជាច្រើនដងជារៀងរាល់ថ្ងៃ។*

*ទីតាំងដែលមានភាពនឹងអាចកើតមានកាន់តែខ្ពស់ នឹងចាំបាច់ត្រូវខិតខំបន្ថែមទៀតដើម្បីកាត់បន្ថយហានិភ័យ - ចាប់ផ្តើមដោយពិនិត្យមើលថាតើហានិភ័យ (នៃផលប៉ះពាល់ពីយានយន្តដែលបណ្តាលឱ្យកំពប់) អាចត្រូវបានលុបបំបាត់ ឬកាត់បន្ថយឬអត់។*

### 3. កម្រិត (ឬផលវិបាក)




ពិចារណាពី **កម្រិត**(ឬផលវិបាក ឬផលប៉ះពាល់លើមនុស្ស ឬបរិស្ថាន) នៃគ្រោះថ្នាក់។ ប្រសិនបើផលប៉ះពាល់នៃគ្រោះថ្នាក់កាន់តែខ្ពស់ នោះអ្នកនឹងត្រូវផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនលើការលុបបំបាត់ ឬការកាត់បន្ថយហានិភ័យ។

កម្រិតនៃការបង្កគ្រោះថ្នាក់មានសារៈសំខាន់កាន់តែខ្លាំងនៅក្នុងជាពិសេសបរិដ្ឋានងាយរងគ្រោះ ដូចជាការនៅក្បែរអ្នកជិតខាង ឬអូរទឹក។ ទោះយ៉ាងណាក៏ដោយ ក្រោមច្បាប់នេះ គ្រោះថ្នាក់រួមបញ្ចូលមានទាំងផលប៉ះពាល់មិនល្អណាមួយដល់បរិស្ថានក្នុងកម្រិតណាមួយ ឬរយៈពេលណាមួយ។ នេះរាប់បញ្ចូលទាំងផលប៉ះពាល់ដែលកើតឡើងបន្តិចម្តងៗតាមពេលវេលា (ត្រូវបានគេស្គាល់ថាជាផលប៉ះពាល់ "គរត្រួតលើគ្នា")។ សូម្បីតែកន្លែងដែលអ្នកស្ថិតនៅតំបន់ឧស្សាហកម្មក៏ដោយ គ្រប់កម្រិតនៃគ្រោះថ្នាក់ដែលអាចកើតមានដល់បរិស្ថាន ឬសុខភាពមនុស្សគឺជាបញ្ហាសំខាន់ ហើយត្រូវតែពិចារណា។

> *ឧទាហរណ៍៖ នៅកន្លែងធ្វើការរបស់ Ahmed ប្រេងម៉ាស៊ីនកំពុងត្រូវបានស្តុកទុកនៅក្បែរប្រឡាយលូបង្ហូរទឹកភ្លៀង។ វាស្ថិតនៅក្នុងតំបន់ដែលបុគ្គលិករបស់គាត់ឆ្លងកាត់ជាញឹកញាប់។ នេះបង្កហានិភ័យដល់បរិស្ថាន និងសុខភាពមនុស្ស។*
>
> *Ahmed ដឹងថាប្រេងម៉ាស៊ីនត្រូវការផ្លាស់ប្តូរ ពីព្រោះវាស្រូបយកនូវសារធាតុបង្កគ្រោះថ្នាក់ជាច្រើន នៅពេលវាត្រូវបានប្រើក្នុងម៉ាស៊ីន និងប្រអប់លេខ។ សារធាតុបង្កគ្រោះថ្នាក់ទាំងនេះរួមមានសារធាតុលោហៈធ្ងន់ និងសារធាតុអ៊ីដ្រូកាបូន។ ប្រសិនបើប្រេងម៉ាស៊ីនចាស់ និងសារធាតុបង្កគ្រោះថ្នាក់ត្រូវបានស្តុកទុកមិនត្រឹមត្រូវ ហើយបណ្តាលឱ្យកំពប់ចូលទៅក្នុងបរិស្ថាន វាអាចបង្កគ្រោះថ្នាក់ដល់មនុស្ស រុក្ខជាតិ និងសត្វ រួមទាំងត្រីផងដែរ។*
>
> ***កម្រិត*** *(ផលវិបាក) នៃគ្រោះថ្នាក់ដែលអាចកើតមាន អាចសំខាន់ចំពោះផ្លូវទឹក និងជីវិតត្រី ប្រសិនបើប្រេងម៉ាស៊ីនចាស់ កំពប់ចូលទៅក្នុងលូបង្ហូរទឹកភ្លៀង។ ការលេចធ្លាយ ឬកំពប់ប្រេងក៏អាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់បុគ្គលិករបស់គាត់ ឬសហគមន៍ដែលនៅក្បែរកន្លែងធ្វើការរបស់គាត់ផងដែរ។*

### 4. ចំណេះដឹងអំពីហានិភ័យ




អ្នកត្រូវបានតម្រូវឱ្យមាន និងស្វែងរកចំណេះដឹងអំពីហានិភ័យដែលសកម្មភាពរបស់អ្នកបង្កទៅដល់បរិស្ថាន និងសុខភាពមនុស្ស។ អ្នកក៏ត្រូវបានតម្រូវឱ្យដឹងពីការដោះស្រាយវាផងដែរ។

ចំណេះដឹងនៃសកម្មភាពរបស់ជនមានកាតព្វកិច្ចម្នាក់នឹងត្រូវបានវាយតម្លៃ រួមមាន៖

- អ្វីដែលពួកគេ *ពិតជាដឹង* និង
- អ្វីដែលនរណាម្នាក់ក្នុងកាលៈទេសៈរបស់ពួកគេ *គួរដឹងដោយសមហេតុផល*អំពីហានិភ័យ។

ទាំងនេះរួមគ្នាបង្កើតជា 'ស្ថានភាពនៃចំណេះដឹង'ដែលជួយកំណត់ទំហំនៃភារកិច្ចរបស់អ្នកមានកាតព្វកិច្ច។ ការទទួលបានចំណេះដឹងនេះមានន័យថា ជាការប្រើប្រាស់ប្រភពដែលគួរឱ្យទុកចិត្ត និងឈ្មោះល្អ។ ចំណេះដឹងដែលមានស្រាប់អាចមកពីអង្គភាពអាជីវកម្ម និងឧស្សាហកម្ម មកពីទីភ្នាក់ងារច្បាប់ និងទីភ្នាក់ងាររដ្ឋាភិបាល ហើយនិងមកពីអង្គការឯករាជ្យ និង/ឬអន្តរជាតិដទៃទៀត។

អ្នកមានចំណេះដឹងកាន់តែច្រើនអំពីហានិភ័យដែលងាយកើតឡើង នោះអ្នកក៏ទំនងជាអាចដឹងមុនពីភាពងាយកើតគ្រោះថ្នាក់ និងធ្វើសកម្មភាពដើម្បីចៀសវាងវា។ ស្រដៀងគ្នានេះដែរ ការខកខានមិនបានទទួលចំណេះដឹងពីអ្នកកាន់កាតព្វកិច្ចផ្សេងទៀត ដែលស្ថិតក្នុងស្ថានភាពដូចគ្នានឹងអ្នក នឹងមានន័យថាអ្នកមិនទំនងជាអាចបំពេញតាមកាតព្វកិច្ចរបស់អ្នកបានទេ។

ក្នុងករណីជាច្រើន កន្លែងណាដែលមានការត្រួតពិនិត្យច្បាស់លាស់ ទទួលយកបាន និងមានប្រសិទ្ធិភាព ឬគម្រូនៃការគ្រប់គ្រងដែលមានចែងក្នុងគោលការណ៍ណែនាំ ក្នុងស្តង់ដារ ឬក្នុងការអនុវត្តឧស្សាហកម្មដែលមានកេរ្តិ៍ឈ្មោះ នេះអាចតំណាងឱ្យការឆ្លុះបញ្ចាំងល្អ អំពីអ្វី *ដែលអាចអនុវត្តបានដោយសមហេតុផល* សម្រាប់ស្ថានភាពរបស់អ្នក។

*ឧទាហរណ៍៖ Ahmed មានកាតព្វកិច្ចដែលចាំបាច់ត្រូវមាន ឬស្វែងរកព័ត៌មានអំពីហានិភ័យ និងការត្រួតពិនិត្យដែលមាន ដើម្បីគ្រប់គ្រងហានិភ័យដែលកើតឡើង ដោយសារតែស្តុកទុកប្រេងម៉ាស៊ីនថ្មី និងប្រេងម៉ាស៊ីនចាស់នៅកន្លែងធ្វើការ។*

*Ahmed ស្រាវជ្រាវការណែនាំឧស្សាហកម្មដែលអាចរកបានសម្រាប់គាត់ អំពីសារធាតុបង្កគ្រោះថ្នាក់នៃប្រេងម៉ាស៊ីនចាស់ និងអំពីការស្តុកទុក និងការបំលាស់ទីនៃវត្ថុរាវដោយសុវត្ថិភាពដូចជាប្រេងជាដើម។ គាត់ធ្វើបែបនេះដោយអានស្លាកនៅលើប្រេងដែលគាត់ប្រើ ហើយស្វែងរកការណែនាំពីឧស្សាហកម្ម និង EPA វិចថូរៀ។ ការណែនាំនេះរួមមានសម្ភារៈសម្រាប់អាន ដូចជាការណែនាំស្តីពីការស្តុកទុក និង ការគ្រប់គ្រងវត្ថុរាវរបស់ EPA (EPA ការបោះពុម្ពផ្សាយ លេខ 1698)។*

*ដោយព្រោះតែ Ahmed ចង់ពង្រឹង **ចំណេះដឹង**របស់គាត់ គាត់ចាប់ផ្តើមស្វែងយល់ពីអ្វីដែលអ្នកផ្សេងទៀតនៅក្នុងឧស្សាហកម្មរបស់គាត់ធ្វើ។ Ahmed ចំណាយពេលនិយាយជាមួយអ្នកឯកទេសក្នុងវិស័យរបស់គាត់ និងសមាគមឧស្សាហកម្មរបស់គាត់ ដើម្បីស្វែងយល់ពីការគ្រប់គ្រង ដែលអ្នកដទៃបង្កើតឡើងដាក់ឱ្យដំណើរការ ដែលអាចមានសម្រាប់គាត់ផងដែរ។ ប្រភពទាំងនេះ រួមគ្នាប្រាប់ពីស្ថានភាពចំណេះដឹងនៅពេលក្នុងចំណុចណាមួយ។*

## 5. ភាពអាចរកបាន




អ្នកត្រូវពិចារណាពីការគ្រប់គ្រងអ្វីខ្លះ **ដែលអាចរកបាន**ព្រមទាំងអ្វីដែល**សមស្រប**ដើម្បីលុបបំបាត់ ឬកាត់បន្ថយហានិភ័យផងដែរ។ នេះមិនមានន័យថា គ្រាន់តែសម្លឹងមើលឧបករណ៍ត្រួតពិនិត្យដើម្បីទិញនោះទេ។ វាក៏អាចមានន័យថា ជាការអនុវត្តការផ្លាស់ប្តូរដំណើរការការងារផងដែរ។

វិធីមួយដេីម្បីលុបបំបាត់ ឬកាត់បន្ថយភាពបង្កគ្រោះថ្នាក់ ឬហានិភ័យជាទូទៅ *ដែលអាចមាន*ប្រសិនបើវា៖

- អាចរកទិញបាន ឬបង្កើតវិធានការត្រួតពិនិត្យ ឬ
- កន្លែងណាដែលវាជាដំណើរការការងារ

វាអាចបំពេញទៅបានក្នុងកាលៈទេសៈរបស់អ្នក។ វិធីដើម្បីលុបបំបាត់

ឬកាត់បន្ថយភាពបង្កគ្រោះថ្នាក់ ឬហានិភ័យជាទូទៅ *ដែលសមស្រប*ប្រសិនបើវា៖

- មានប្រសិទ្ធភាពក្នុងការលុបបំបាត់ ឬកាត់បន្ថយភាពនឹងអាចកើតមាន ឬកម្រិតនៃគ្រោះថ្នាក់ពីភាពបង្កគ្រោះថ្នាក់ ឬហានិភ័យ
- មិនបង្កើតហានិភ័យថ្មីៗ និងខ្លាំងជាងនេះ នៅក្នុងគ្រប់កាលៈទេសៈទាំងអស់
- គឺជាវិធានការជាក់ស្តែង ដោយគិតអំពីកាលៈទេសៈដែលមានភាពបង្កគ្រោះថ្នាក់ ឬហានិភ័យ។




នៅពេលពិចារណាលើបញ្ហាទាំងនេះ អ្នកអាចគិតអំពីលំដាប់នៃការគ្រប់គ្រង។ ឧទាហរណ៍ ប្រសិនបើមិនអាចរកបានបច្ចេកវិទ្យា ឬឧបករណ៍ជឿនលឿនដើម្បីគ្រប់គ្រងហានិភ័យទេ (មានន័យថា អ្នកមិនអាច **លុបបំបាត់**ហានិភ័យបានទេ) អ្នកអាចពិចារណាការគ្រប់គ្រងផ្សេងទៀត ដូចជាការផ្លាស់ប្តូរសកម្មភាពទៅកាន់ទីតាំងនៅកន្លែងមួយផ្សេងវិញ (ដែលមានសុវត្ថិភាពជាង) (**ការគ្រប់គ្រងបែបវិស្វកម្ម**)ឬតាមរយៈការបណ្តុះបណ្តាលបុគ្គលិករបស់អ្នកអំពីវិធីដ៏មានប្រសិទ្ធិភាព ដើម្បីអនុវត្តសកម្មភាពដែលកាត់បន្ថយហានិភ័យ (**ការគ្រប់គ្រងផ្នែករដ្ឋបាល**)។

*ឧទាហរណ៍៖ Ahmed អាចកំណត់វិធានការត្រួតពិនិត្យដែលអាចរកបាន ដោយពិភាក្សាពីសកម្មភាពរបស់គាត់ ជាមួយអ្នកផ្គត់ផ្គង់របស់គាត់។ គាត់ក៏អាចស្រាវជ្រាវជម្រើសគ្រប់គ្រងហានិភ័យដែលមានសម្រាប់លក់ ឬដំណើរការថ្មីៗដែលគាត់អាចយកលំនាំបាន ដោយរក្សាការធ្វើឱ្យទាន់ផ្ទៃកឧស្សាហកម្ម និងការណែនាំរបស់ EPA។ ឧទាហរណ៍ បច្ចុប្បន្ននេះ ដំណោះស្រាយក្នុងការទប់ស្កាត់ការលេចធ្លាយប្រេងផ្សេងៗអាចរកបានដែល Ahmed អាចពិចារណាដើម្បីប្រើប្រាស់។*

*Ahmed អាចពិចារណាថាតើការត្រួតពិនិត្យមានលក្ខណៈសមស្របសម្រាប់កាលៈទេសៈរបស់គាត់ឬអត់ តាមរយៈការស្វែងយល់ពីរបៀបដែលវាដំណើរការ តើការផ្លាស់ប្តូរអ្វីខ្លះដែលគាត់ចាំបាច់ត្រូវធ្វើឡើងដល់ទីតាំង ឬដំណើរការរបស់គាត់ ហើយថាតើជម្រើសមានប្រសិទ្ធិភាពដូចម្តេចដើម្បីគ្រប់គ្រងហានិភ័យ។ ជម្រើសមួយចំនួនប្រហែលជាមិនសមស្របទេ ដោយសារតែភាពបង្កគ្រោះថ្នាក់ផ្សេងទៀតនៅលើទីតាំងរបស់គាត់។ ឧទាហរណ៍ ប្រដាប់ប្រដាការពារការកំពប់ប្រេងដែលអាចរកបាន ប្រហែលជាមិនសមស្របសម្រាប់ការប្រើប្រាស់នៅលើទីតាំងរបស់គាត់ទេ ដោយសារតែភាពងាយឆេះនៃប្រេងម៉ាស៊ីនដែលកំពប់។ Ahmed ត្រូវពិនិត្យមើល ថាតើឧបករណ៍មួយណាដែលត្រូវសមគ្នានឹងប្រេង។*

*Ahmed ក៏អាចពិចារណាប្រើសញ្ញានានា ដើម្បីកាត់បន្ថយហានិភ័យនៃការបុកប៉ះទង្គិចផងដែរ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើសញ្ញាទាំងនោះបង្ហាញជាភាសាអង់គ្លេស នេះប្រហែលជាមិនសមស្របសម្រាប់បុគ្គលិកទាំងអស់ក្នុងក្រុមរបស់គាត់ទេ។ ក្នុងករណីនេះ Ahmed ចាំបាច់ត្រូវប្រើសញ្ញានានាដែលមានពណ៌ និងរូបភាព ដែលនឹងបញ្ជាក់ច្បាស់ពីហានិភ័យនៃការបើកបរក្នុងទីកន្លែងដែលមានទុកផុងប្រេងម៉ាស៊ីនចាស់។*

## 6. ថ្លៃចំណាយ




ថ្លៃចំណាយនៃដំណោះស្រាយជាក់លាក់ដែលកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ ត្រូវតែពិចារណាប្រៀបធៀបទៅនឹងការកាត់បន្ថយហានិភ័យដែលអាចសម្រេចបាន។

ជាសំខាន់ ដំណោះស្រាយដែលមានប្រសិទ្ធភាពបំផុត មិនតែងតែមានតម្លៃខ្ពស់នោះទេ។ ដូចគ្នានេះដែរ ដំណោះស្រាយដែលមានតម្លៃថោកជាង ប្រហែលជាមិនមានប្រសិទ្ធភាពបំផុតដើម្បីគ្រប់គ្រងហានិភ័យនោះទេ។

ឧទាហរណ៍ ការដំឡើងការគ្រប់គ្រងបែបវិស្វកម្ម អាចនឹងចំណាយច្រើន ប៉ុន្តែទាំងនេះអាចត្រឹមត្រូវ ចំពោះកន្លែងណាដែលវាកាត់បន្ថយហានិភ័យយ៉ាងច្រើន ជាពិសេសកន្លែងណាដែលការគ្រប់គ្រងផ្នែករដ្ឋបាល ដូចជាការបណ្តុះបណ្តាលទំនងជាមិនដំណើរការល្អ។ ដូចគ្នានេះដែរ យូរៗទៅការរក្សា *ការគ្រប់គ្រងផ្នែករដ្ឋបាល*ប្រកបដោយប្រសិទ្ធភាព (ដូចជាការបណ្តុះបណ្តាលទៀងទាត់ និងការពិនិត្យបញ្ជាក់) អាចនឹងត្រូវចំណាយច្រើន ជាងវិធានការត្រួតពិនិត្យដែលមិនតម្រូវការធ្វើបច្ចុប្បន្នភាពជាប្រចាំ។

អ្នកទំនងជាបានបំពេញកាតព្វកិច្ចរបស់អ្នក ចំពោះស្តង់ដារ *ដែលអាចអនុវត្តបានដោយសមហេតុផល* នៅពេលអ្នកអាចបង្ហាញថា ការបង្កើនធនធានរបស់អ្នកដើម្បីកាត់បន្ថយហានិភ័យ បែរជាមិនផ្តល់ឱ្យមានការកាត់បន្ថយសំខាន់នៃហានិភ័យនោះទេ។ នេះមានន័យថា អ្នកអាចពិចារណា៖

- បើការវិនិយោគដែលតម្រូវដើម្បីអនុវត្តការគ្រប់គ្រង មិនសមាមាត្រគ្នានឹងហានិភ័យនៃគ្រោះថ្នាក់ ដូច្នេះការអនុវត្តការគ្រប់គ្រងនោះ មិនបានចាត់ទុកថា *អាចអនុវត្តបានដោយសមហេតុផលទេឬ*
- ការអនុវត្តការគ្រប់គ្រងដែលមានតម្លៃថ្លៃ ឬការប្រើប្រាស់ធនធានកាន់តែច្រើន បែរជានឹងមិនផ្តល់ឱ្យមានភាពប្រសើរឡើងដែលអាចកំណត់បាន ក្នុងការគ្រប់គ្រងហានិភ័យ។

ការគិតគូរលើបញ្ហាទាំងនេះមិនមែនមានន័យថា អ្នកមិនចាំបាច់គ្រប់គ្រងហានិភ័យរបស់អ្នកនោះទេ ប៉ុន្តែវាអាចជួយអ្នកក្នុងការកំណត់ ថាតើអ្នកមានអ្វីដែលមានប្រសិទ្ធភាពរួចជាស្រេចនៅនឹងកន្លែង ឬការគ្រប់គ្រងផ្សេងទៀតដែលអ្នកកំពុងសុំយកមកអនុវត្ត មានប្រសិទ្ធិភាពដូចគ្នាក្នុងការលុបបំបាត់ ឬកាត់បន្ថយហានិភ័យឬទេ។

ជាញឹកញាប់ ការប្រើរួមបញ្ចូលគ្នានៃការត្រួតពិនិត្យហានិភ័យដើម្បីកាត់បន្ថយហានិភ័យ នឹងផ្តល់ផលចំណេញផ្នែកហិរញ្ញវត្ថុ ច្រើនជាងវិធានការគ្រប់គ្រងហានិភ័យតែមួយ ហើយនឹងទទួលបានកម្រិតស្មើគ្នានៃការកាត់បន្ថយហានិភ័យ។

## ដែលអាចអនុវត្តបានដោយសមហេតុផល

*ឧទាហរណ៍៖ Ahmed បានកំណត់នូវរាល់ការគ្រប់គ្រងសមស្របដែលមានសម្រាប់គាត់ដើម្បីគ្រប់គ្រងហានិភ័យនៃគ្រោះថ្នាក់ដែលបង្កឡើងដោយការស្តុកទុកប្រេងម៉ាស៊ីនថ្មី និងប្រេងម៉ាស៊ីនចាស់នៅនឹងកន្លែង។*

*Ahmed កំពុងថ្លឹងថ្លែងអនុវត្តការត្រួតពិនិត្យពីរបីដែលមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យ។ Ahmed ដឹងថា ការត្រួតពិនិត្យជាច្រើនដែលអាចរកបានសម្រាប់គាត់ គឺសាមញ្ញ* ***ចំណាយតិច*** *និងងាយស្រួលអនុវត្ត។ ទោះយ៉ាងណាក៏ដោយ ការត្រួតពិនិត្យមួយចំនួនដែលអាចមានសម្រាប់ Ahmed ផងដែរនោះ គឺមានតម្លៃថ្លៃ ហើយប្រើប្រាស់ធនធានកាន់តែច្រើនដើម្បីអនុវត្ត។ Ahmed នឹងគិតអំពីថាតើការចំណាយលើការអនុវត្តការគ្រប់គ្រងទាំងនោះ មានសមាមាត្រទៅនឹងអត្ថប្រយោជន៍ដែលអាចមាន ហើយដែលវាអាចនាំឱ្យកាត់បន្ថយហានិភ័យបន្ថែមទៀតឬអត់។*

# ដែលអាចអនុវត្តបានដោយសមហេតុផល

*ឥឡូវនេះ Ahmed បានពិចារណាៈ*




1. *តើខ្ញុំអាចលុបបំបាត់ហានិភ័យ (លុបបំបាត់) បានឬទេ?*
2. *តើមានឱកាសដែលគ្រោះថ្នាក់នឹងកើតមាន (ភាពនឹងអាចកើតមាន) ឬទេ?*
3. *តើគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬបរិស្ថាន (កម្រិត ឬផលវិបាក) អាចធ្ងន់ធ្ងរប៉ុណ្ណា?*
4. *តើខ្ញុំដឹងពីអ្វីខ្លះ ឬតើខ្ញុំអាចស្វែងយល់ពីអ្វីខ្លះអំពីហានិភ័យ (ចំណេះដឹង)?*
5. *តើបច្ចេកវិទ្យា ដំណើរការ ឬឧបករណ៍អ្វីខ្លះដែលមាន ហើយសមស្របដើម្បីគ្រប់គ្រងហានិភ័យ (ភាពអាចរកបាន និងភាពសមស្រប)?*
6. *តើការចំណាយនៃជម្រើសត្រួតពិនិត្យ ប្រៀបធៀបនឹងគ្រោះថ្នាក់ដែលគួរជៀសវាងមានយ៉ាងដូចម្តេចដែរ?*

*Ahmed អាចប្រើការគិតពិចារណានេះ ដើម្បីបង្ហាញថាការគ្រប់គ្រងដែលគាត់អនុវត្តដើម្បីលុបបំបាត់ ឬកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ គឺ**អាចអនុវត្តបានដោយសមហេតុផល**។*

## ដែលអាចអនុវត្តបានដោយសមហេតុផល អាចវិវត្តទៅតាមពេលវេលា

ស្ថានភាពចំណេះដឹងស្តីពីហានិភ័យដល់សុខភាពមនុស្ស និងបរិស្ថាន មានភាពប្រសើរឡើងទៅតាមពេលវេលា។ ចំណេះដឹងថ្មីៗស្តីពីហានិភ័យ ហើយឱកាសថ្មីៗដើម្បីគ្រប់គ្រងហានិភ័យឱ្យបានកាន់តែប្រសើរ កើតឡើងតាមរយៈបច្ចេកវិទ្យា និងបច្ចេកទេសថ្មី ដែលមានតម្លៃសមល្មមនឹងចំណាយបាន។ ល្បឿននៃការផ្លាស់ប្តូរ ឬការកែលម្អនៃចំណេះ គឺខុសៗគ្នាសម្រាប់ឧស្សាហកម្ម និងសកម្មភាពទាំងអស់។

អ្នកមានកាតព្វកិច្ច ចាំបាច់ត្រូវពិនិត្យ សើរើមើលហានិភ័យដែលកើតឡើងពីសកម្មភាព និងពិនិត្យសើរើមើលប្រសិទ្ធភាពនៃវិធីសាស្រ្តរបស់ពួកគេ ចំពោះការគ្រប់គ្រងហានិភ័យដែលកំពុងមាន នៅខណៈពេលមានជម្រើសថ្មីៗមកដល់។

អ្នកក៏គួរតែពិនិត្យសើរើមើលការយល់ដឹងរបស់អ្នកជាទៀងទាត់អំពីភាពនឹងអាចកើតមាន និងផលវិបាកនៃសកម្មភាពរបស់អ្នក ហើយនិងការគ្រប់គ្រងដែលអ្នកមាន ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងបរិស្ថានផងដែរ។ តាមរយៈការធ្វើដូចនេះ អ្នកអាចធានាថាអ្នកបន្តបំពេញការយល់ដឹងបច្ចុប្បន្ន អំពីអ្វីដែលអាចអនុវត្តបានដោយសមហេតុផល។

## ធនធានដែលមាន

សម្រាប់ព័ត៌មានបន្ថែមអំពីការរៀបចំអាជីវកម្មរបស់អ្នក ដើម្បីត្រៀមសម្រាប់ច្បាប់ថ្មីនានា អ្នកអាចប្រើប្រាស់ធនធានខាងក្រោមដើម្បីជួយអ្នក៖

- *ការណែនាំឧស្សាហកម្ម៖ គាំទ្រអ្នកឱ្យអនុវត្តតាមកាតព្វកិច្ចបរិស្ថានទូទៅ* (ការបោះពុម្ពផ្សាយ EPA លេខ 1741)
- ការគ្រប់គ្រងហានិភ័យផ្នែកបរិស្ថាន
- *ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ៖ ការណែនាំសម្រាប់អាជីវកម្ម* (ការបោះពុម្ពផ្សាយ EPA លេខ 1695)
- epa.vic.gov.au/for-business

## សេចក្តីថ្លែងការណ៍អំពីការទទួលស្គាល់

EPA ទទួលស្គាល់ប្រជាជននៃប្រជាជាតិលើកដំបូងរបស់រដ្ឋវិចថូរៀ និងកម្លាំងដែលកំពុងបន្តរបស់ពួកគេ ក្នុងការអនុវត្តវប្បធម៌រស់នៅចំណាស់ជាងគេបំផុតនៅលើពិភពលោក។
យើងទទួលស្គាល់ចំពោះម្ចាស់ទឹកដីជាប្រពៃណីដែលយើងរស់នៅ និងធ្វើការ ហើយសម្តែងការគោរពដល់ចាស់ទុំទាំងពីអតីតកាល និងបច្ចុប្បន្ន។

យើងទទួលស្គាល់ថា៖

- ដី និងទឹកមានសារៈសំខាន់ខាងវិញ្ញាណ វប្បធម៌ និងសេដ្ឋកិច្ច ដល់ជនជាតិដើម។
- ទីកន្លែងទាំងអស់ក្នុងរដ្ឋវិចថូរៀ មាននៅលើទឹកដីប្រពៃណីរបស់ជនជាតិដើមវិចថូរៀ។
- ផលប្រយោជន៍ តម្រូវការ និងសេចក្តីប្រាថ្នារបស់ជនជាតិដើម គឺសំខាន់ចាំបាច់សម្រាប់បញ្ចូលទៅក្នុងអាជីវកម្មស្នូលរបស់ EPA។

នៅក្នុងការទទួលស្គាល់ និងការគោរពចំពោះការកាន់កាប់បរិស្ថានរាប់ពាន់ឆ្នាំ ជនជាតិដើមវិចថូរៀ និងវប្បធម៌របស់ពួកគេ គឺសំខាន់ចាំបាច់សម្រាប់ការបញ្ចូលទៅក្នុងប្រយោជន៍ខាងបទប្បញ្ញត្តិរបស់ EPA ដើម្បីការពារសុខភាពមនុស្ស និងបរិស្ថាន ពីផលប៉ះពាល់ដ៏គ្រោះថ្នាក់ដែលបង្កឡើងដោយការបំពុល និងកាកសំណល់។
ជាផ្នែកនៃវិធីសាស្រ្តបទប្បញ្ញត្តិរបស់យើង យើងស្វែងរកការចូលរួម និងការធ្វើការរួមគ្នា ដើម្បីបង្កើតបរិយាកាសការងារប្រកបដោយសុវត្ថិភាព ហើយមានលក្ខណៈវប្បធម៌ដែលរាប់បញ្ចូលទាំងទស្សនវិស័យ និងគុណតម្លៃរបស់ជនជាតិដើម។

EPA សូមលើកទឹកចិត្តឱ្យប្រជាជនវិចថូរៀទាំងអស់ ពិចារណាចំពោះវិធីដែលពួកគេអាចទទួលស្គាល់ គោរព និងការពារបេតិកភណ្ឌវប្បធម៌របស់ជនជាតិដើមផងដែរ។